# ព័ត៌មានអំពីច្បាប់សុខភាពផ្លូវចិត្ត និងសុខុមាលភាពថ្មីរបស់រដ្ឋវិចថូរៀ

Khmer | ភាសាខ្មែរ

**OFFICIAL**

## ច្បាប់សុខភាពផ្លូវចិត្ត និងសុខុមាលភាពថ្មីរបស់រដ្ឋវិចថូរៀ

សន្លឹកព័ត៌មាននេះមានព័ត៌មានដើម្បីជួយអ្នកឱ្យយល់ដឹងអំពីច្បាប់សុខភាពផ្លូវចិត្ត និងសុខុមាលភាពថ្មីរបស់រដ្ឋវិចថូរៀ (*ច្បាប់សុខភាពផ្លូវចិត្ត និងសុខុមាលភាពឆ្នាំ 2022*)។

ច្បាប់ថ្មីនេះគឺផ្អែកលើសិទ្ធិមនុស្ស។ វាមានគោលបំណង៖

- ជួយមនុស្សឱ្យមានសុខភាពផ្លូវចិត្តល្អ
- ការពារមនុស្សដែលមានជំងឺផ្លូវចិត្ត
- ជួយគ្រួសារ និងអ្នកថែទាំមនុស្សដែលមានជំងឺផ្លូវចិត្ត។

ច្បាប់ថ្មីនេះមានគោលការណ៍នានាដើម្បីធ្វើឱ្យប្រាកដថាសេវាកម្មសុខភាពផ្លូវចិត្ត និងសុខុមាលភាពនានាមានសុវត្ថិភាពសម្រាប់មនុស្សគ្រប់រូប។ នេះមានន័យថាសេវាកម្មទាំងនេះមានលក្ខណៈរួមបញ្ចូល និងអាចចូលប្រើប្រាស់បាន។

គោលការណ៍ទាំងនេះនិយាយថាសេវាកម្មសុខភាពផ្លូវចិត្តទាំងនេះត្រូវតែគោរពមនុស្សទាំងអស់ដែលនៅក្នុងសហគមន៍ រួមមានមនុស្សដែលមកពីវប្បធម៌ ក្រុមភាសា និងប្រវត្តិសាវតាជំនឿខុសៗគ្នា។

## សេចក្តីថ្លែងស្តីពីសិទ្ធិ

ច្បាប់ថ្មីនិយាយថាមនុស្សម្នាក់ត្រូវតែបានផ្តល់ឱ្យនូវសេចក្តីថ្លែងអំពីសិទ្ធិ ប្រសិនបើពួកគេកំពុងទទួលបានជំនួយសម្រាប់សុខភាពផ្លូវចិត្តរបស់ពួកគេនៅក្នុងមន្ទីរពេទ្យ។

សេចក្តីថ្លែងស្តីពីសិទ្ធិគឺជាឯកសារមួយដែលពន្យល់អំពីសិទ្ធិស្របច្បាប់របស់មនុស្សម្នាក់។ បុគ្គលិកនៅមន្ទីរពេទ្យត្រូវតែជួយឱ្យមនុស្សម្នាក់យល់ដឹងអំពីសេចក្តីថ្លែងនៃសិទ្ធិនានា។

សេចក្តីថ្លែងស្តីពីសិទ្ធិត្រូវបានបកប្រែជាភាសាសហគមន៍នានា ហើយវាអាចរកបាននៅលើគេហទំព័ររបស់ក្រសួងសុខាភិបាលនៅឯ [www.health.vic.gov.au/mental-health-and-wellbeing-act](www.health.vic.gov.au/mental-health-and-wellbeing-act)

## សេចក្តីថ្លែងជាមុនស្តីពីចំណង់ចំណូលចិត្ត

សេចក្តីថ្លែងជាមុនស្តីពីចំណង់ចំណូលចិត្តគឺនៅពេលមនុស្សម្នាក់សរសេរអំពីអ្វីដែលពួកគេពិតជាចង់បាន និងមិនចង់បាននៅក្នុងការព្យាបាល និងការថែទាំសុខភាពផ្លូវចិត្តរបស់ពួកគេ។

សេចក្តីថ្លែងជាមុនស្តីពីចំណង់ចំណូលចិត្តអាចនិយាយអំពីរបៀបដែលមនុស្សម្នាក់ចង់បានជំនួយ ប្រសិនបើពួកគេទទួលបានការព្យាបាលជាចាំបាច់។ ឧទាហរណ៍ ពួកគេអាចនិយាយថាពួកគេមិនចង់បានឱសថខ្លះ។

បុគ្គលិកត្រូវតែព្យាយាមធ្វើតាមនូវអ្វីដែលមាននៅក្នុងសេចក្តីថ្លែងនោះ។ ប្រសិនបើបុគ្គលិកមិនធ្វើតាមនូវអ្វីដែលមាននៅក្នុងសេចក្តីថ្លែងទេ ពួកគេត្រូវតែកត់ត្រាទុកអំពីមូលហេតុ។

បុគ្គលម្នាក់អាចធ្វើសេចក្តីថ្លែងជាមុនស្តីពីចំណង់ចំណូលចិត្ត នៅពេលណាក៏បាន។

# បុគ្គលគាំទ្រដែលបានតែងតាំង

បុគ្គលគាំទ្រដែលបានតែងតាំង គឺជានរណាម្នាក់ដែលជាមនុស្សជ្រើសរើសដើម្បីជួយពួកគេ ប្រសិនបើពួកគេមានការព្យាបាលដែលជាចាំបាច់។

បុគ្គលគាំទ្រដែលបានតែងតាំងអាចជួយមនុស្សម្នាក់៖

- ធ្វើសេចក្តីសម្រេចនានាអំពីការព្យាបាល និងការថែទាំសុខភាពផ្លូវចិត្ត
- ប្រាប់វេជ្ជបណ្ឌិតអំពីអ្វីដែលមនុស្សនោះចង់បាន។

មនុស្សម្នាក់ត្រូវតែកត់ត្រាទុកអ្នកដែលចង់ធ្វើជាបុគ្គលគាំទ្រដែលបានតែងតាំង ហើយពួកគេត្រូវតែយល់ព្រមធ្វើជាបុគ្គលគាំទ្រដែលបានតែងតាំង។

# ការតស៊ូមតិក្រៅផ្លូវច្បាប់

មានសេវាកម្មមួយហៅថាសេវាកម្មតស៊ូមតិសុខភាពផ្លូវចិត្តក្រៅផ្លូវច្បាប់។

ការតស៊ូមតិក្រៅផ្លូវច្បាប់មានន័យថា អ្នកទទួលបានជំនួយពីនរណាម្នាក់ដែលមិនមែនជាមេធាវី។ មនុស្សនេះហៅថាអ្នកតស៊ូមតិ។

ប្រសិនបើមនុស្សម្នាក់ទទួលការព្យាបាលជាចាំបាច់ ពួកគេត្រូវតែបានផ្តល់ជូនជំនួយពីអ្នកតស៊ូតមតិម្នាក់។ មនុស្សនោះអាចនិយាយថាទេ ប្រសិនបើពួកគេមិនចង់បានអ្នកតស៊ូមតិទេ។

ឈ្មោះសេវាកម្មនេះគឺការតស៊ូមតិសុខភាពផ្លូវចិត្តឯករាជ្យ (IMHA)។

# គណៈកម្មការសុខភាពផ្លូវចិត្ត និងសុខុមាលភាព

គណៈកម្មការសុខភាពផ្លូវចិត្ត និងសុខុមាលភាពថ្មី ជួយធ្វើឱ្យប្រាកដថាសេវាកម្មសុខភាពផ្លូវចិត្តនានាមានសុវត្ថិភាព និងអាចរកបានដល់មនុស្សទាំងអស់។

ប្រសិនបើមនុស្សនោះមិនសប្បាយចិត្តជាមួយនឹងសេវាកម្មសុខភាពផ្លូវចិត្ត និងសុខុមាលភាព ពួកគេអាចប្រាប់គណៈកម្មការនេះ។ គណៈកម្មការនេះនឹងស្តាប់ ហើយព្យាយាមស្វែងរកដំណោះស្រាយ។

# តើព័ត៌មានត្រូវបានប្រើប្រាស់ និងចែករំលែកយ៉ាងដូចម្តេច?

ច្បាប់ថ្មីនិយាយថាសេវាកម្មសុខភាពផ្លូវចិត្ត និងសុខុមាលភាពអាចចែករំលែកព័ត៌មានជាមួយមនុស្សដទៃទៀតបាន

- ប្រសិនបើមនុស្សម្នាក់និយាយថា បាទ/ចាស
- ឬជួនកាលដើម្បីរក្សាមនុស្សម្នាក់មានសុវត្ថិភាព និងស្ថានភាពល្អ។

នៅក្រោមច្បាប់ថ្មី ព័ត៌មានអាចត្រូវបានចែករំលែកជាមួយសេវាកម្មដទៃទៀត ដើម្បីផ្តល់ឱ្យមនុស្សនូវការគាំទ្រល្អបំផុតដែលអាចធ្វើទៅបាន។

នេះអាចជា

- សេវាកម្មផ្ទះសម្បែង
- សេវាកម្មទាក់ទងនឹងគ្រឿងញៀន និងស្រវឹង។

មនុស្សម្នាក់អាចជ្រើសរើស ប្រសិនបើពួកគេចង់ចែករំលែកជាមួយសេវាកម្មដទៃទៀត។

ព័ត៌មានក៏អាចត្រូវបានចែករំលែកផងដែរជាមួយសេវារថយន្តសង្គ្រោះបន្ទាន់នៅក្នុងគ្រាមានអាសន្ន។

# តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមទៀតនៅកន្លែងណា?

សម្រាប់ព័ត៌មានថ្មីៗបំផុត សូមចូលមើលទំព័រ mental-health-and-wellbeing-act
<https://www.health.vic.gov.au/mental-health-and-wellbeing-act>
នៅលើគេហទំព័រក្រសួងសុខាភិបាលនៃរដ្ឋវិចថូរៀ។

ដើម្បីទទួលឯកសារនេះជាទម្រង់ដទៃទៀត សូមអ៊ីមែលទៅ mhwa@health.vic.gov.au <mhwa@health.vic.gov.au>។

ផ្តល់សិទ្ធិអនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលរដ្ឋវិចថូរៀ 1 Treasury Place, Melbourne។

© រដ្ឋវិចថូរៀ ក្រសួងសុខាភិបាល ខែសីហា ឆ្នាំ 2023។

ISBN 978-1-76131-225-0 (អនឡាញ/PDF/Word)

អាចរកបាននៅគេហទំព័រ ច្បាប់សុខភាពផ្លូវចិត្ត និងសុខុមាលភាព <https://www.health.vic.gov.au/mental-health-and-wellbeing-act>